**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
លេខ: ០២៩ /០៨ក.ហ.អគគ

## កំណត់ហេតុ ស្តីពី កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ

ឆ្នាំពីរពាន់ប្រាំបី ខែ តុលា ថ្ងៃទី ដប់ប្រាំ វេលាម៉ោងដប់បួន និងសាមសិបនាទី នៅសាលប្រជុំ A11 នៃទី ស្តីការគណៈរដ្ឋមន្ត្រី (អតីតរដ្ឋសភា) មានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពរបស់ឯកឧត្តម សំ សុខផល ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីពិនិត្យ និងពិភាក្សាពីភាពបន្ត លើកិច្ចការរបស់ក្រុមការងារបច្ចេកទេស ចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម សំ សុខផល បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាតំណាងក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធមួយចំនួន និងមន្ត្រីអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះក្នុងថ្ងៃនោះ ។ ក្នុងឱកាសនោះដែរ ឯកឧត្តមប្រធានបានថ្លែងថា ថ្ងៃនេះគឺជាថ្ងៃប្រជុំលើកដំបូង របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ បន្ទាប់ពីបានពន្យាពេលអស់រយៈពេល៣ខែ ដើម្បីរង់ចាំ ការរៀបចំរដ្ឋាភិបាលថ្មី ។ ទោះបីជាយ៉ាងណាក៏ដោយលទ្ធផលនៃការបោះឆ្នោតបានបង្ហាញពីភាពជោគជ័យ និងភាពស៊ីសង្វាក់គ្នានៃផែនការកំណែទម្រង់ នៅក្នុងការធ្វើកំណែទម្រង់រដ្ឋ ហើយចំពោះកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ក៏ជាកំណែទម្រង់មួយដែលត្រូវបានបន្តការអនុវត្តនៅក្នុងទិសដៅជាយុទ្ធសាស្ត្រទាំងប្រាំពីរ ផងដែរ ។ ជាបន្ទាប់ឯកឧត្តមបានធ្វើសេចក្តីរាយការណ៍ពីខែ ០៦ ឆ្នាំ ២០០៨ និងជាការផ្តល់ព័ត៌មានដល់ អង្គប្រជុំទាំងមូលដូចតទៅ ៖

1- សេចក្តីព្រាងចរាចរស្តីពីនីតិវិធីនៅក្នុងការធ្វើច្បាប់ (Guideline) បានពិនិត្យរួចរាល់ហើយដោយកិច្ច ប្រជុំលើកទីមួយរបស់ក្រុមប្រឹក្សាអ្នកច្បាប់ និង OBSESS ពីរអាទិត្យមុនការឃោសនាបោះឆ្នោត គឺស្ថិតនៅក្នុង ខែមិថុនា ឆ្នាំ ២០០៨ កន្លងទៅនេះ បច្ចុប្បន្ននេះកំពុងរង់ចាំរបៀបវារៈនៅអន្តរ ក្រសួង ឬយោបល់បន្ថែមរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ។
2- សេចក្តីព្រាងក្រមព្រហ្មទណ្ឌប្រហែល៧០៣មាត្រា បានធ្វើការពិនិត្យរួចដោយកិច្ច ប្រជុំលើកទី១ នៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៨ ក្នុងនោះមាន ២២៤ មាត្រា ត្រូវបានសម្រេចអនុម័តរួចហើយ ។ ក្រុមការងារបច្ចេកទេសរបស់ក្រុមប្រឹក្សាអ្នកច្បាប់ និងក្រសួងយុត្តិធម៌

បានសហការគ្នា នៅក្នុងការបង្កើតក្រុមនេះ ។ នៅពេលជាមួយគ្នានេះដែរសម្តេចនាយករដ្ឋមន្ត្រី បានកំណត់នៅក្នុង កិច្ចប្រជុំលើកទី១របស់គណៈរដ្ឋមន្ត្រី នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ដោយបានសម្រេចអោយ ក្រសួង និងអាជ្ញាធរដែលពាក់ព័ន្ធ ជាមួយ នឹងការរៀបចំច្បាប់ប្រឆាំងអំពើពុករលួយ គឺគួរតែរៀបចំ សេចក្តីព្រាងច្បាប់នោះអោយហើយ ។

3- នៅពាក់កណ្តាលខែសីហា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាអ្នកច្បាប់បានបើកកិច្ចប្រជុំមួយ ដោយមានការចែករំលែកនូវគំនិតអំពីការបង្កើតតុលាការរដ្ឋបាល និងតុលាការបច្ចេកទេស ផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ។ ដើម្បីជៀសវាងភាពស្មុគ្រស្មាញក្នុងនីតិវិធី និងការអនុវត្តដោយមិនធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ក្រុមប្រឹក្សាអ្នកច្បាប់ត្រូវធ្វើការបង្ហាញ និងផ្តល់យោបល់ចំពោះការរៀបចំតុលាការបច្ចេកទេស ដើម្បីអោយស្របទៅនឹងស្ថានភាពបច្ចុប្បន្ន ។ ក្រុមប្រឹក្សាអ្នកច្បាប់នឹង ធ្វើការពិនិត្យនូវច្បាប់ផ្សេងៗទៀត បូករួមទាំងសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់តុលាការ និងសេចក្តីព្រាងច្បាប់ស្តីពីការធ្វើវិសោធនកម្មនៃឧត្តមក្រុមប្រឹក្សា និងសេចក្តីព្រាង ច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ។ ក្រសួងយុត្តិធម៌ជាមួយនឹងសំណើរបស់ ក្រុមប្រឹក្សាអ្នកច្បាប់បានធ្វើការពិនិត្យម្តងទៀតនូវសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ដើម្បីធ្វើជូនគណៈរដ្ឋមន្ត្រីធ្វើការអនុម័ត ។

4- គណៈកម្មការសន្ទានុក្រមជាតិ បានបន្តកិច្ចប្រជុំដើម្បីបង្កើតក្រុមការងារផ្នែកច្បាប់នៅ តាមបណ្តា ក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធនានា រាជរដ្ឋាភិបាលបានឯកភាពគ្នា ប្រើប្រាស់ពាក្យដែលអនុម័ត ដោយគណៈកម្មការក្នុងការធ្វើសេចក្តីព្រាងច្បាប់ ។

5- ក្រុមប្រឹក្សាអ្នកច្បាប់ ក្រោមការផ្តល់យោបល់របស់ឯកឧត្តមនាយករដ្ឋមន្ត្រីបានរៀបចំបង្កើតព្រះរាជក្រិត្យ ដើម្បីកំណត់អំពីរចនាសម្ព័ន្ធរបស់សមាជិក ចំពោះការដោះស្រាយបណ្តឹងរដ្ឋបាល ។

លោកស្រី Momoko Hotta, មកពី Jica ទាក់ទងនឹងការបង្កើតតុលាការជំនាញ បានចោទជាសំណួរថា តើមានច្បាប់អ្វីក្នុងការបង្កើតតុលាការពិសេសនេះ ? ហើយមួយទៀតក្រសួងពាណិជ្ជកម្មចង់បង្កើតតុលាការ ពាណិជ្ជកម្មដាច់ដោយឡែកមួយដែរ ក្នុងរឿងនេះជំនាញ Jica ក៏កំពុងតែធ្វើការសម្របសម្រួលក្នុងបញ្ហានេះផងដែរ ។ លោកស្រីបានសួរទៀតថា តើត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីអោយតុលាការពាណិជ្ជកម្មនេះស្របគ្នា និងស៊ីសង្វាក់គ្នាទៅនឹងតុលាការបច្ចុប្បន្ន ? ។ លោកស្រីបានលើកឡើងផងដែរចំពោះភាពមិនស្របគ្នា និងស៊ីសង្វាក់គ្នា ជាពិសេសគឺមិនស្របជាមួយក្រម នីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ហើយយើងកំពុង តែជជែកគ្នារវាងក្រសួងពាណិជ្ជកម្ម និង UNDP ដែលជាអ្នកជួយគាំទ្រដល់ផ្នែកនេះ ដើម្បីធ្វើការសម្របសម្រួលធ្វើយ៉ាងណាអោយមានលក្ខណៈស៊ីសង្វាក់គ្នា មិនត្រឹមតែក្រុមប្រឹក្សាអ្នកច្បាប់ប៉ុណ្ណោះទេ សូម្បីតែ រដ្ឋាភិបាលទាំងមូលក៏គួរតែមានគោលនយោបាយរបស់រដ្ឋាភិបាលនៅក្នុងប្រព័ន្ធតុលាការដែរ ។ ក្រុមប្រឹក្សាអ្នក ច្បាប់អាចពិនិត្យមើលលក្ខណៈលំអិត និងធ្វើយ៉ាងណាអោយប្រព័ន្ធតុលាការនេះ មានលក្ខណៈស៊ីសង្វាក់គ្នា និងស្របគ្នា ។

ឯកឧត្តម សំ សុខផល បានបញ្ជាក់ថា បញ្ហាដែលលោកស្រីបានលើកឡើងខាងលើនេះ មានលក្ខណៈសំខាន់ណាស់ ។ ប៉ុន្តែឯកឧត្តមបានលើកឡើងពីផលវិបាករបស់ឯកឧត្តមផ្ទាល់ក្នុង ការសម្របសម្រួល ជាមួយស្ថាប័ន និងអង្គភាពផ្សេងៗទៀត ដើម្បីធ្វើយ៉ាងណាអោយច្បាប់ទាំងបីនេះចេញទៅរួច ( គឺ សេចក្តីព្រាង ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការចាត់តាំង និងការប្រព្រឹត្តទៅរបស់តុលាការ និងច្បាប់ ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ) ។ នៅក្នុងការដោះស្រាយបញ្ហានេះ បើតាមគំនិតរបស់ ឯកឧត្តមផ្ទាល់គឺទាំងរាជរដ្ឋាភិបាល និងតុលាការ ត្រូវតែ សហការរួមគ្នាធ្វើច្បាប់ទាំងអស់នេះអោយចេញរួច ។ ឯកឧត្តមប្រធានបានលើកឡើងជុំវិញមតិមួយចំនួនថា ប្រសិនបើគ្មានការកែប្រែរដ្ឋធម្មនុញ្ញទេ យើងមិនអាចបង្កើតតុលាការទាំងអស់នោះបានទេ ដូចជា តុលាការ រដ្ឋបាល និងតុលាការឯកទេសជាដើម ។ ហើយបើតាមយោបល់ខាងវិស័យតុលាការវិញ គឺមិនចង់អោយមានការប្រែរដ្ឋធម្មនុញ្ញនោះឡើយនៅក្នុងអាណត្តិទី៤នេះ ដូច្នេះយើងត្រូវតែរកមធ្យោបាយផ្សេងទៀត ។ ឯកឧត្តមបាន ជម្រាបផងដែរថា ប្រហែលជា១០ថ្ងៃកន្លងមក ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទីស្តី ការគណៈរដ្ឋមន្ត្រីបានផ្តល់យោបល់ថា ក្រុមប្រឹក្សាអ្នកច្បាប់អាចដើរតួនាទីពីរ ទី១-តុលាការរដ្ឋបាល និងទី២ តួនាទីក្នុងតុលាការកំពូល ។ យើងកំពុងតែធ្វើការសិក្សា ធ្វើសេចក្តីព្រាងព្រះរាជក្រឹត្យមួយ ដើម្បីអោយក្រុមប្រឹក្សាអ្នកច្បាប់ ដើរតួនាទីនេះបាន ហើយជំហានបន្ទាប់ទៀត យើងមានច្បាប់កំណត់ជាក់លាក់ច្បាស់ចំណែកកិច្ចសហប្រតិបត្តិការបារាំងកំពុងធ្វើសេចក្តីព្រាងនូវការបង្កើតតុលាការរដ្ឋបាលនេះឡើង រួមទាំងនីតិ វិធីផង ។

លោកស្រី Momoko Hotta, Jica បានមានប្រសាសន៍សង្កត់ធ្ងន់ថា អ្វីដែលលោកស្រីចង់បាននោះគឺចង់អោយ រាជរដ្ឋាភិបាលមានក្របខណ្ឌច្បាប់មួយជាគោលនយោបាយជាក់លាក់ ដើម្បីបញ្ចៀសការខ្វែងគំនិតគ្នារវាងតុលាការទូទៅ និងតុលាការឯកទេស ។ លោកស្រីបញ្ជាក់ថាខាងដៃគូអភិវឌ្ឍន៍ជួយគាំទ្រ និងអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលយើង ។

តំណាង Danida បានផ្តល់ជាយោបល់ទាក់ទងជាមួយច្បាប់ជាមូលដ្ឋាននោះថា ដើម្បីជៀសវាងកុំអោយមានការជាន់គ្នានោះ រដ្ឋាភិបាលគួរតែរៀបចំបង្កើតផែនការសកម្មភាពមួយ ។ ដើម្បីអនុម័តច្បាប់ជាមូលដ្ឋាន នោះអោយបានចេញ ប្រសិនបើមានបញ្ហាអ្វីមួយដែលធ្វើអោយមានភាពរាំងស្ទះនោះ យើងត្រូវតែលើកយក បញ្ហានោះ មកធ្វើការពិភាក្សាគ្នា ដើម្បីរកដំណោះស្រាយ ។

ឯកឧត្តម សំ សុខផល បានបំភ្លឺទៅតំណាង Danida ថា ដើម្បីអនុម័តច្បាប់ជាមូលដ្ឋាននោះអោយបានចេញ រាជរដ្ឋាភិបាលអាណត្តិទី៣ បានបង្កើតអនុក្រុមជាច្រើនដើម្បីធ្វើការតាមដានទៅលើច្បាប់ទាំងនេះ ។ ទាក់ទងនឹងការអនុម័តច្បាប់នេះ ឯកឧត្តមបានជម្រាបជូនថា ឯកឧត្តមនឹងពិភាក្សា

ជាមួយនឹងឯកឧត្តម អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ថា នឹងត្រូវធ្វើយ៉ាងណា ដើម្បីពន្លឿនដំណើរការអនុម័តច្បាប់នេះ ។

លោក កុយ នាម តំណាង UNDP បានចូលរួមចំណែកក្នុងការផ្តល់ ជាមតិយោបល់ខ្លះពីបញ្ហារដ្ឋធម្មនុញ្ញ និងតុលាការពិសេសរបស់យើង ។ ជាមួយគ្នានោះដែរ លោកបានលើកយកការពិភាក្សារៀបចំរដ្ឋធម្មនុញ្ញពាក់ព័ន្ធនឹងប្រព័ន្ធ តុលាការតាំងពីឆ្នាំ១៩៩៣ ដោយកាលនោះ ខាងជំនាញការបារាំងចង់បែងចែកតុលាការជាពីរផ្នែក គឺ តុលាការរដ្ឋបាល និងតុលាការពិសេសដោយឡែក ប៉ុន្តែនៅពេលនោះអតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានប្រកាន់ខ្ជាប់ដោយយកប្រព័ន្ធតុលាការតែមួយ ព្រោះគ្រាន់តែចង់ជៀសវាងអ្វីដែលមានបន្ទាប់ធ្វើមកនៅ រដ្ឋកម្ពុជាតែប៉ុណ្ណោះ ។ ដូច្នេះលោកយល់ថា មិនចាំបាច់កែប្រែរដ្ឋធម្មនុញ្ញនោះទេ ។

លោកស្រីតំណាង French Cooperation បានជម្រាបថា ខាងកិច្ចសហប្រតិបត្តិការបារាំងរង់ចាំការបង្កើត ការងារចម្រុះសម្រាប់ធ្វើសេចក្តីព្រាងតុលាការរដ្ឋបាលនេះ។ លោកស្រីបានសួរថា តើក្រមព្រហ្មទណ្ឌត្រូវចំណាយ ពេលវេលាប៉ុន្មានខែទៀត ដើម្បីចេញរួច ?

ឯកឧត្តម សំ សុខផល បានបំភ្លឺថា ចំពោះក្រមព្រហ្មទណ្ឌនេះ គឺត្រូវចំណាយពេលប្រហែលជាពីរឬបីខែទៀត ព្រោះក្រោយពីកិច្ចប្រជុំលើកទី១ រួចទៅ កិច្ចប្រជុំលើកទី២ គឺអន្តរក្រសួងមិនចំណាយពេលយូរទេព្រោះក្រុមប្រឹក្សាអ្នកច្បាប់ និងក្រសួងយុត្តិធម៌បានពិនិត្យពីរឬបីលើកមកហើយ ។ ឯកឧត្តមបានបញ្ជាក់ថាក្រមនេះនឹងដាក់បញ្ជូនទៅអន្តរ ក្រសួងក្នុងខែវិច្ឆិកាខាងមុខនេះ ។

ជាបន្ទាប់ឯកឧត្តមប្រធានបានអញ្ជើញឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាព គ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ធ្វើការបង្ហាញពីសូចនាករថ្មី និងសូចនាករចាស់ (JMI 2007 ) និងច្បាប់ ជាមូលដ្ឋានក្នុងវិស័យតុលាការ ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានមានប្រសាសន៍ថា ការពិភាក្សាថ្ងៃនេះមានការទាក់ទងទៅសូចនាករ តាមដានរួមថ្មី ។ កាលពី ពីរទៅបីសប្តាហ៍កន្លងទៅនេះឯកឧត្តមបានទទួលសំណើពីខាង GDCC ចំនួនពីរ ទី១- របាយការណ៍ស្តីពីភាពជឿនលឿន និងបញ្ហាប្រឈមមុខ ទី២-សំណើអំពីសូចនាករថ្មី ។ ឯកឧត្តមបានបញ្ជាក់ថា រាជរដ្ឋាភិបាលមានប្រធានក្រុមការងារបច្ចេកទេស និងលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសចម្រុះ សហការគ្នាជាមួយអ្នកសម្របសម្រួលនៅ ក្នុងក្រុមការងារ បច្ចេកទេសបានរៀបចំឯកសារដោយមានជំនួយពីទីប្រឹក្សា បច្ចេកទេសគឺលោក Ben Schultz រីឯឯកសារបានចែកជូនក្រុមការងារបច្ចេកទេសរួចអស់ហើយ ដើម្បី រួមគ្នាជួយពិនិត្យមើល ។ ខាង GDCC បានកំណត់អោយមាន JMI តែមួយទេសម្រាប់ក្រុមការងារបច្ចេកទេស នីមួយៗ ហើយសកម្មភាពក៏មានយ៉ាងច្រើនពីរប៉ុណ្ណោះ ។ ដូច្នេះយើងរក្សា JMI ចាស់កាលពីឆ្នាំ ២០០៧ គឺការ រៀបចំប្រព័ន្ធច្បាប់ និងតុលាការ

អោយមានដំណើរការល្អប្រកបដោយគណនីយ្យភាពតម្លាភាព និងការពារសិទ្ធិ បុគ្គល ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដូច្នេះយើងមានសកម្មភាពពីរៈ

ទី១- អនុម័តច្បាប់ទាំងបីពាក់ព័ន្ធនឹងតុលាការ និងក្រមព្រហ្មទណ្ឌ ។

ទី២- ការចុះអនុវត្តនូវក្របខ័ណ្ឌកំណែទម្រង់ច្បាប់ និងតុលាការមាន ៖

ក-ការចុះអនុវត្តការចុះបញ្ជីសំណុំរឿងនៅតាមតុលាការគំរូទាំងបួនមាន កណ្តាល ភ្នំពេញ កំពង់ចាម និង បន្ទាយមានជ័យ ។

ខ-បន្តការធ្វើការបណ្តុះបណ្តាល និងជ្រើសរើសមន្ត្រីបំរើការផ្នែកតុលាការ ដើម្បីផ្តល់ការកែលំអរ សេវាយុត្តិធម៌ និងតុលាការ ។

បញ្ហាមួយទៀតទាក់ទងនឹងតុលាការគំរូ ខាងក្រុមការងារជាន់ខ្ពស់តុលាការគំរូបានសម្រេច ផ្ទេរកិច្ចការតុលាការគំរូនេះទៅក្រសួងយុត្តិធម៌ នៅពេលណាការធ្វើផែនការការងារតុលាការគំរូ នេះត្រូវបានធ្វើរួចនៅក្នុងនោះមានសូចនាករតាមដានថ្មីមួយដែរ ។ ទាក់ទងការកំណត់កាលបរិច្ឆេទដែល អាចវាស់វែងបានអោយសម្រេចបានក្នុងរយៈពេលពី ១៥ខែ ទៅ១៨ខែ ។ ឯកឧត្តមបានបញ្ជាក់ អំពីសៀវភៅចុះបញ្ជីសំណុំរឿងតុលាការ ដែលទីប្រឹក្សា CCJAP III ប្រចាំនៅក្រសួងយុត្តិធម៌ បានរៀបចំជាមួយក្រសួងយុត្តិធម៌រួច សព្វគ្រប់អំពីរបៀបនៃ ការចុះបញ្ជីព័ត៌មាន និងរបៀបបំពេញព័ត៌មាន នេះ ហើយនៅពេលដែលយើងត្រូវធ្វើកិច្ចការនេះ យើងមានទម្រង់ Format ស្រាប់ ។ ឯកសារទាំងនេះក្រុមការងារបច្ចេកទេសបានបញ្ជូនទៅ GDCC រួចហើយ ។

លោកស្រី Momoko បានមានប្រសាសន៍ថា កំណត់សូចនាករតាមដានថ្មី គឺជាការល្អយើងគួរផ្តោតទៅលើសូចនាករថ្មីដែលកំណត់ JMIfµIeGayបានជោគជ័យក្នុងការធ្វើទំនើបក្របខណ្ឌច្បាប់ និងការអនុវត្ត ។

- សំណួរទី១ លោកស្រីបានសួរថា តើការយករយៈពេលពី ១៥ខែ ទៅ១៨ខែនោះ ផ្តោតទៅលើតែការចុះបញ្ជី សំណុំរឿងឬយ៉ាងណា ?
- សំណួរទី២ទាក់ទងនឹងសកម្មភាព ៉ x ៉ ថាតើគួរធ្វើការបណ្តុះបណ្តាលបន្ត ឬយល់ថា ការបណ្តុះបណ្តាល បឋមជាការសំខាន់ ឬគួរតែធ្វើទាំងពីរ ?
- សំណួរទី៣ ការជ្រើសរើសប្រកបដោយតម្លាភាព ថាតើធ្វើយ៉ាងណាដើម្បីអោយគោរពបាន និង សម្រេចក្នុងរយៈពេលពី ១៥ខែ ទៅ១៨ខែនោះ ហើយតើដៃគូអភិវឌ្ឍន៍អាចជួយធ្វើអ្វីខ្លះ (គួរផ្តោត ទៅលើរដ្ឋបាលតុលាការ ឬផ្តោតទៅលើគុណភាពនៃការបណ្តុះបណ្តាល ) ?

ឯកឧត្តម ស៊ុយ ម៉ុងលាង បានឆ្លើយតបទៅលោកស្រី Momoko ថា យើងធ្លាប់មានបទពិសោធន៍កន្លងមក កាលណាដាក់សូចនាករថ្មីមានចំនួនច្រើន មិនអាចសម្រេចលទ្ធផលបានទេ ។ ទាក់ទងនឹងសំណួរទី១ ចំពោះការចុះបញ្ជីសំណុំរឿង យើងអាចមើលទៅលើទម្រង់ កន្លែងណាដែលត្រូវដាក់ព័ត៌មានលំអិតច្រើនដែល ត្រូវបំពេញ នៅពេលអនុវត្តគម្រោងនេះ និងមានធ្វើការបណ្តុះបណ្តាលក្រឡាបញ្ជី ដើម្បីងាយបំពេញព័ត៌មាន នេះបានដល់ចំណុចដែលយើងអាច ស្វែងរកដៃគូអភិវឌ្ឍន៍និងម្ចាស់ជំនួយជួយដល់ការងារធ្វើការបណ្តុះបណ្តាលនេះ ។ ចំពោះការបណ្តុះបណ្តាលនេះ គឺផ្តោត

ទៅលើពីរចំណុច គឺ ផ្តោតទៅលើគុណភាព និងការជ្រើសរើសប្រសិនបើដៃគូអភិវឌ្ឍន៍មិនមានអ្វីដែលត្រូវធ្វើទាក់ទងនឹងការជ្រើសរើសនេះទេ យើងអាចដកចំណុចនេះ ចេញក៏បានដែរ ។ យើងផ្តោតទៅលើតែគុណភាពនៃការបណ្តុះបណ្តាល បានហើយ ។

តំណាង ACU បានសួរថា តើច្បាប់ប្រឆាំងអំពើពុករលួយកំពុងស្ថិតនៅឯណា ?

លោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការក្រសួងយុត្តិធម៌ បានបញ្ជាក់ប្រាប់ថា ច្បាប់នេះបានរុញទៅសាម៉ីក្រសួងរួចរាល់ហើយ លោកជំទាវបានមានប្រសាសន៍ថា បើចង់ដឹងព័ត៌មាននេះ អាចសួរទៅសាម៉ី ក្រសួង គឺក្រសួងទំនាក់ ទំនងសភា និងអធិការកិច្ច ។

លោកស្រី Momoko បានបង្ហាញជូននូវគោលបំណងគាំទ្រការរៀបចំប្រមូលចងក្រង ព័ត៌មានទាក់ទងដល់ជំនួយឧបត្ថម្ភរបស់ដៃគូអភិវឌ្ឍន៍ទាំងអស់លើសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ ។ ឯកឧត្តម ស៊ុយ ម៉ុងលាង ក៏គាំទ្រមតិរបស់លោកស្រីតំណាង JICApgEdr ។

តំណាង USAID បានជម្រាបជូនព័ត៌មានមួយដែរទាក់ទងទៅនឹងកម្មវិធីសិទ្ធិ និងយុត្តិធម៌របស់ USAID ដែលត្រូវបានបញ្ចប់ ហើយនឹងបន្តគម្រោងរយៈពេលប្រាំឆ្នាំទៀត រហូតដល់ឆ្នាំ ២០១៣ ដោយមាន EWMI ជាអ្នកអនុវត្ត.

ទីបញ្ចប់ ឯកឧត្តម សំ សុខផល បាន ថ្លែងអំណរគុណ ចំពោះការចូលរួមពិគ្រោះយោបល់ក្នុងអង្គប្រជុំទាំងមូល និងសម្រេចថា បន្តកិច្ចប្រជុំលើកក្រោយនៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨ ខាងមុខនេះ ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងប្រាំល្ងាចនាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨*

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង

អ្នកធ្វើរបាយការណ៍

ស៊ុយ ម៉ុងលាង

សេង វ៉ាន់ដា ស៊ុន សិរីរ៉ុធ

បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា
នាថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៨

០១-ឯកឧត្តម សំ សុខផល ប្រធានក្រុមការងារបច្ចេកទេសចម្រុះ
០២-ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៣-ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៤- ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៥- ឯកឧត្តម បួន សុមុនី នាយករងអង្គភាពគ្រប់គ្រងគម្រោង
០៦- លោកជំទាវ ចាន់ សុទ្ធាវី ក្រសួងយុត្តិធម៌
០៧-លោក ជឹង ផេងស្រួយ ប្រធានក្រុមគម្រោងបណ្ណសារ និងព័ត៌មានវិទ្យា ក.ក.ច.ន.យ
០៨-លោក ឃ្លោក ដារ៉ា ប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម
០៩-លោក Ben Schultz, Adviser (CCJAP III)
១០- Hou Sthabna ACU
១១- Heng Sokheang, ACU
១២- Lies Dahl, UNDP
១៣- Reed Aeshliman, USAID
១៤- Koy Neam, UNDP
១៥- លោកស្រី សាខឿន សារ៉ាត់ឌី ក្រសួងកិច្ចការនារី
១៦-ឯកឧត្តម Kheang Seng, ACU
១៧- Mrs.Momoko Hotta (Assistant Resident Representative, JICA )
១៨- Mr. Rajan Shah (Access to Justice Advisor) EWMI
១៩- Mr. Ros Chhay, AusAid
២០- Ms. Lesley Miller ( UNICEF Chief Child Protection )
២១- Ms.Orthi Patel, AusAid
២២- Mr. Michael Engquist, Senior Program Officer, Danida
២៣- Pork Phira, JICA
២៤- Mr. Elies Hermoso, Assistant French Cooperator
២៥-ម៉ាង ម៉ូនីកា សហប្រតិបត្តិការបារាំង
២៦-ហ៊ិន យុវនា ក្រសួងមហាផ្ទៃ
២៧- ឯម សំបូរឧត្តម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
២៨- លោក ជ សៀកវេង CCJAPIII
២៩-លោកស្រី ឈូក សារ៉ុម មន្ត្រី
៣០-កញ្ញា ផាន់ ពីសីនលក្ខណ៍ មន្ត្រី ក.ក.ច.ន.យ

៣១-លោក ស៊ុន សិរីវុធ ជំនួយការរដ្ឋបាល